01117935

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 07 / 2015
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/22/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ (ឯកសារ E319/22)។ កំណត់ហេតុដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ជ នៃសំណើសុំ (ឯកសារ E319/22.1) គឺជាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៣ និង ០០៤ ដែលត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញា នៅខែ កុម្ភៈ ខែ មីនា និង ខែមេសា ឆ្នាំ ២០១៥ (សូមមើល ឯកសារ E319/13 ឯកសារ E319/15 ឯកសារ E319/19 ឯកសារ E319/20 និង ឯកសារ E319/21)។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា កំណត់ហេតុស្តាប់ចម្លើយទាំង

នោះ "ជាប់ពាក់ព័ន្ធដោយផ្ទាល់" ទៅនឹងអង្គហេតុមួយចំនួននៃសំណុំរឿង ០០២/០២ ជាពិសេសពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់ ១ មករា និង សិទ្ធិអំណាច រចនាសម្ព័ន្ធ និង ការបោសសម្អាតភូមិភាគពាយ័ព្យ និង ភូមិភាគកណ្ដាល (ឧត្ដរចាស់) (ឯកសារ E319/22 កថាខណ្ឌ ២)។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា កំណត់ហេតុទាំងនេះពាក់ព័ន្ធនឹងការស្ដាប់ចម្លើយដែលបានធ្វើក្រោយពេលចាប់ផ្ដើមជំនុំជម្រះក្នុងខែ មិថុនា ឆ្នាំ ២០១១ ហើយថា គាត់ទើបតែទទួលបានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិឱ្យបង្ហាញចម្លើយទាំងនេះក្នុងសំណុំរឿង ០០២ នៅឆ្នាំនេះប៉ុណ្ណោះ (ឯកសារ E319/11 កថាខណ្ឌ ៣)។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា កំណត់ហេតុទាំងនេះមិនអាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះឡើយ (ឯកសារ E319/11 កថាខណ្ឌ ៣)។ ពុំមានភាគីណាមួយឆ្លើយតបទៅនឹងសំណើសុំនេះទេ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងថ្មីដែលអង្គជំនុំជម្រះយល់ថាមានប្រយោជន៍ក្នុងការស្វែងរកការពិត ហើយថា ភ័ស្តុតាងនេះក៏ត្រូវបំពេញទៅតាមបទដ្ឋាន*តាមការវិភាគបឋម* នៃភាពជាប់ពាក់ព័ន្ធ ភាពអាចជឿជាក់បាន និង យថាភាព ដែលតម្រូវដោយវិធាន ៨៧(៣)។ វិធាន ៨៧(៤) ក៏ចែងផងដែរថា ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភ័ស្តុតាងដែលបានស្នើសុំមិនអាចរកបាននៅមុនពេលចាប់ផ្ដើមជំនុំជម្រះ ឬ មិនអាចរកបាន បន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់ដោយសមស្របរួចហើយ។ អង្គជំនុំជម្រះធ្លាប់បានបញ្ជាក់ពីមុនមកហើយថា ឯកសារដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដំបូងរបស់ភាគីអនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង គឺជាភ័ស្តុតាងថ្មី ដែលត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ប៉ុន្តែ ឯកសារនេះអាចទទួលយកបាននៅពេលដែលប្រយោជន៍យុត្តិធម៌តម្រូវដូច្នេះ (ឯកសារ E282/2 កថាខណ្ឌ ៣ យោងទៅ ឯកសារ E190 កថាខណ្ឌ ១៩ ដល់ ២១)។

៣. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា ទោះបីបញ្ជីឯកសារដែលភាគីបានដាក់ក្នុងឆ្នាំ ២០១១ បានគ្របដណ្ដប់ទៅលើសំណុំរឿង ០០២ ទាំងមូលក៏ដោយ តែអង្គជំនុំជម្រះបានសម្រេចជាការលើកលែងមួយថា បញ្ជីនានាដែលបានដាក់នៅឆ្នាំ ២០១៤ គឺជាសំណៅកែសម្រួលទៅលើបញ្ជីឆ្នាំ ២០១១ ដែលត្រូវបានអនុញ្ញាត។ កាលបរិច្ឆេទដែលយកមកគិត ដើម្បីពិចារណាថាតើ

01117937



ភ័ស្តុតាង អាច ឬ មិនអាចរកបាន មុនពេលចាប់ផ្តើមជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ គឺឆ្នាំ ២០១១ (ឯកសារ E307/1/2)។ កំណត់ហេតុស្តាប់ចម្លើយដែលមានរៀបរាប់ក្នុង ឧបសម្ព័ន្ធ ជ ត្រូវបានដកស្រង់ចេញពីការស្តាប់ចម្លើយដែលបានធ្វើឡើងចន្លោះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ និង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ ហេតុនេះ មិនអាចរកបាននៅមុនពេល ជំនុំជម្រះទេ។ បន្ថែមពីលើនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុញ្ញាតឱ្យ បង្ហាញកំណត់ហេតុស្តាប់ចម្លើយទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ យ៉ាងហោចណាស់ ក្រោយថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ហើយ កំណត់ហេតុស្តាប់ចម្លើយទាំងនេះមិនអាចត្រូវ បានអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ក្នុងឯកសារ E307/1/2 នោះទេ។

៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយត្រូវបានធ្វើឡើងដោយអ្នក ស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហេតុនេះ កំណត់ហេតុស្តាប់ចម្លើយទាំង នេះបានបំពេញបទដ្ឋាន*តាមការវិភាគបឋម*នៃភាពអាចជឿជាក់បាន និង យថាភាព។

៥. អង្គជំនុំជម្រះបានពិនិត្យទៅលើកំណត់ហេតុទាំងនោះ ហើយពិចារណាឃើញថា កំណត់ហេតុ ស្តាប់ចម្លើយ ពីលេខ ១ ដល់ ៥៨ នៅក្នុងឧបសម្ព័ន្ធ ជ របស់សហព្រះរាជអាជ្ញាអន្តរជាតិ មានព័ត៌មានសក្តានុពលស្តីពីការដ្ឋានទំនប់ត្រពាំងថ្ម ហើយភាគច្រើនជាប់ពាក់ព័ន្ធនឹងបញ្ហា សំខាន់ៗក្នុងសំណុំរឿង ០០២/០២ (ឧទាហរណ៍ ឯកសារ E319/19.3 ទំព័រ ៥ ស្តីពីការ ប្រព្រឹត្តិចំពោះជនជាតិវៀតណាម ឯកសារ E319/19.3.8 ទំព័រ ៥ ស្តីពីបទបញ្ជាសម្រាប់ការ រៀបអាពាហ៍ពិពាហ៍)។ ហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា កំណត់ហេតុស្តាប់ចម្លើយទាំងនេះ មានប្រយោជន៍ក្នុងការស្វែងរកការពិត និង ជាប់ពាក់ព័ន្ធ*តាមការវិភាគបឋម* ទៅនឹងសំណុំ-រឿង ០០២/០២។

៦. អង្គជំនុំជម្រះពិចារណាឃើញទៀតថា កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីការស្តាប់ ចម្លើយដែលនៅសេសសល់ផ្សេងទៀត មានចម្លើយនានាដែលពាក់ព័ន្ធនឹងប្រធានបទជាច្រើន ដែលមានក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ជាពិសេស៖ ឯកសារដែលមានលេខ ៥៩, ៦០ ដល់ ៦៦, ៦៨, ៧៥ ដល់ ៧៦, ៧៨ ដល់ ៨០, ៨៣ ដល់ ៨៦, ៨៨ នៅក្នុងឧបសម្ព័ន្ធ ជ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង; ឯកសារលេខ ៦៧ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា; ឯកសារលេខ ៧០ ដល់ ៧៣ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល (ជាពិសេស ពាក់ព័ន្ធនឹងត្រាំកក់); ឯកសារលេខ ៧៤ ពាក់ព័ន្ធនឹងបទបញ្ជាសម្រាប់ការរៀប

អាពាហ៍ពិពាហ៍; ឯកសារ ៧៧, ៨១, ៨២ និង ៨៧ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ និង ឯកសារលេខ ៨៩ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខក្រាំងតាចាន់។ ឯកសារលេខ ៨៩ ត្រូវបានលើកឡើងរួចហើយនៅក្នុងអំឡុងពេលសវនាការនៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ ហើយភាគីនានាពុំបានជំទាស់ទៅនឹងការទទួលយកឯកសារនេះទេ។ លើសពីនេះទៀត ឯកសារទាំងនេះភាគច្រើនក៏ជាប់ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗផ្សេងៗទៀតក្នុងសំណុំរឿង ០០២/០២ (ឧទាហរណ៍ ឯកសារ E319/19.3.79 ស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសន្និដ្ឋានថា ចម្លើយទាំងនេះមានប្រយោជន៍ក្នុងការស្វែងរកការពិត និងជាប់ពាក់ព័ន្ធ*ភាពការវិភាគបឋម* ទៅនឹងសំណុំរឿង ០០២/០២។

៧. ហេតុដូច្នេះ អង្គជំនុំជម្រះសន្និដ្ឋានថា លក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ ហើយអង្គជំនុំជម្រះឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយនានាដែលបានលើកឡើងខាងលើដើម្បីធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសាលាដំបូងរម្លឹកទៅភាគីនានាថា ការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវស្ថិតក្រោមលក្ខខណ្ឌតម្រូវនានាផ្នែកនីតិវិធីដែលមានរៀបរាប់នៅក្នុងសេចក្តីសម្រេចនៃឯកសារ E319/7។

៨. អនុស្សរណៈនេះជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/22។